៤.៤ **សមាគមអភិវឌ្ឍន៍គ្រួសារពលី និងកុមារកំព្រា** មានសិទ្ធិបញ្ឈប់សកម្មភាពភ្លាមលើកិច្ចព្រមព្រៀងនេះ ក្រោយពីបានពិភាក្សាជាមួយក្រសួង **សង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា** ប្រសិនជាគេពិនិត្យឃើញថាគ្មានកិច្ចសហប្រតិបត្តិការគ្រប់គ្រាន់សំរាប់ការអនុវត្តន៍គំរោងអោយមានប្រសិទ្ធិភាពឬសន្តិសុខនៃបុគ្គលិកឬទ្រព្យសម្បត្តិរបស់ខ្លួនស្ថិតក្នុងគ្រោះថ្នាក់ដោយសង្គ្រាមដោយអរិភាព ឬដោយការរំខានធ្ងន់ធ្ងរណាមួយ ។

៤.៥ បន្ទាប់ពីបានពិភាក្សាជាមួយអង្គការរួច និងផ្អែកលើយោបល់របស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិក្រសួង **សង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា** នឹងស្នើអោយអង្គការបញ្ឈប់ការងារចំពោះបុគ្គលិកណាដែលត្រូវបានគេវិនិច្ឆ័យថាធ្វើអោយខូចកិត្តិយសក្រសួងបានប្រព្រឹត្តខុសនឹងក្រមសីលធម៌វិជ្ជាជីវៈរបស់ខ្លួន ។ ប្រសិនជាមានសំណើបែបនេះ **សមាគមអភិវឌ្ឍន៍គ្រួសារពលី និងកុមារកំព្រា** ត្រូវអនុវត្តតាមដំណើរការសមគួរណាមួយ ។

៤.៦ ក្រោយពីបានពិភាក្សាជាមួយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC) និងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្រសួង **សង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា** មានសិទ្ធិបញ្ឈប់កិច្ចព្រមព្រៀងនេះប្រសិនបើតំណាងផ្លូវការរបស់ **សមាគមអភិវឌ្ឍន៍គ្រួសារពលី និងកុមារកំព្រា** ត្រូវបានគេវិនិច្ឆ័យឃើញថាមិនបានបំពេញតាមមាត្រា ២ នៃកិច្ចព្រមព្រៀងនេះ ។

៤.៧ ប្រសិនបើគេរកឃើញថា **សមាគមអភិវឌ្ឍន៍គ្រួសារពលី និងកុមារកំព្រា** មិនគោរពតាមច្បាប់របស់ព្រះរាជាណាចក្រកម្ពុជាក្រសួង **សង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា** អាចបញ្ឈប់កិច្ចព្រមព្រៀងនេះ បន្ទាប់ពីជូនពតិមានដល់សាមីអង្គការនោះរួចមក ។

៤.៨ កិច្ចព្រមព្រៀងនេះមានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាដូចមានចែងក្នុងចំណុច ១.៤ នៃកិច្ចព្រមព្រៀងនេះ ។

*កិច្ចព្រមព្រៀងនេះរៀបចំឡើងដោយឥតកែប្រែ មួយច្បាប់ជាភាសាខ្មែរ ។*

បានចុះហត្ថលេខានៅរាជធានីភ្នំពេញ កម្ពុជា ថ្ងៃទី ......១៣...... ខែ...ឧសភា... ឆ្នាំ ......២០០៣......

**ហត្ថលេខី**

| | |
|---|---|
| **តំណាងក្រសួង សង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា** | **តំណាងសមាគមអភិវឌ្ឍន៍គ្រួសារពលី និងកុមារកំព្រា** |
| នៃរាជរដ្ឋាភិបាលកម្ពុជា | |
| ហត្ថលេខា | ហត្ថលេខា |
| ឈ្មោះ......**វង ស៊ុត** | ឈ្មោះ......**ចើន ស៊ីណា**...... |
| តួនាទី......**អនុរដ្ឋលេខាធិការ** | តួនាទី......នាយកប្រតិបត្តិ |

១